**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជាអធិដ្ឋានសម្រាប់ការត្រាស់ហៅនៅព្រះសហគមន៍សន្តសិលានិងសន្តប៉ូល**
**ភ្នំពេញថ្មី ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩**

# ព្រះសហគមន៍ជាឪពុកម្ដាយរបស់បូជាចារ្យ

**អត្ថបទទី១៖ រ៉ូម ១៤,៧-១២**

ដ្បិតព្រះគ្រីស្តបានសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ដើម្បីធ្វើជាព្រះអម្ចាស់ទាំងលើមនុស្សស្លាប់ទាំងលើមនុស្សរស់។ រម ១៤,៩

**ដំណឹងល្អ៖ លូកា ១៥,១-១០**

ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ទេវទូតរបស់ព្រះជាម្ចាស់នឹងមានអំណរសប្បាយជាខ្លាំង ដោយមានមនុស្សបាបតែម្នាក់កែប្រែចិត្តគំនិត។ លក ១៥,១០

បងប្អូនជាទីស្រឡាញ់!

អត្ថបទទីមួយ ដែលយើងបានស្ដាប់អាចទៅជាមេរៀនសម្រាប់ជីវិតរបស់យើង ដើម្បីនឹកឃើញអំពីរបៀបដែលយើងរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ។ "**ហេតុដូចម្ដេចបានជាអ្នកថ្កោលទោសបងប្អូនរបស់អ្នក? ហេតុដូចម្ដេចបានជាអ្នកមើលងាយបងប្អូនរបស់អ្នក? យើងទាំងអស់គ្នានឹងទៅឈរនៅមុខតុលាការរបស់ព្រះជាម្ចាស់**" ជួនកាលយើងពូកែមើលងាយគេ ពូកែនិយាយដើមគេ ពូកែមើលកំហុសគេ ប៉ុន្តែយើងភ្លេចមើលយើងផ្ទាល់ខ្លួន។ ប៉ុន្មានអាទិត្យនេះ ព្រះយេស៊ូមានពាក្យប្រស្នាច្រើន ថ្ងៃនេះព្រះយេស៊ូបានចូលនៅក្នុងផ្ទះ និងញ៉ាំបាយជាមួយអ្នកទារពន្ធ ណែនាំឲ្យមនុស្សដែលនៅជុំវិញគេឆ្ងល់ហេតុអ្វីព្រះយេស៊ូនៅជាមួយអ្នកបាប។ ប៉ុន្មានថ្ងៃ ព្រះយេស៊ូបាននៅជាមួយគេរហូតដើម្បីអប់រំគេ ដើម្បីបង្រៀនគេ ដើម្បីណែនាំផ្លូវឲ្យគេ។ មុនយើងនិយាយអំពីព្រះគម្ពីរ យើងត្រូវតែសាបព្រោះដើម្បីឲ្យមានមនុស្សមួយចំនួនស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឲ្យមានមនុស្សមួយចំនួនចាប់ផ្ដើមចាប់អារម្មណ៍អំពីជីវិតរបស់ព្រះសហគមន៍ ឲ្យយើងមានឱកាសអប់រំជំនឿដល់គេ។

សម្រាប់យើងដែលជាគ្រីស្តបរិស័ទ **តើខ្ញុំធ្វើអ្វីខ្លះដើម្បីប្រកាសជំនឿ?** នៅក្នុងគម្ពីរមានបុរសម្នាក់ដែលចេញទៅចម្ការនឹងគាត់បានសាបព្រោះ នៅពេលយើងចាប់ផ្ដើមឆ្នាំថ្មីតាមព្រះសហគមន៍នីមួយៗ យើងត្រូវការអង្គុយរិះគិតអំពីរបៀបដែលយើងត្រូវសាបព្រោះ។ ធ្វើដូចម្ដេចដើម្បីទៅជាសាក្សីនៃដំណឹងល្អដែលជាទ្រព្យសម្បត្តិដែលយើងបានទទួល នៅក្នុងរូបកាយ នៅក្នុងចិត្តទន់ខ្សោយរបស់យើង។ យើងធ្វើដូចម្ដេច ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ចែករំលែកជាមួយមនុស្សយ៉ាងច្រើន ឲ្យគេមានឱកាសដើម្បីស្ដាប់ ដើម្បីឮ ដើម្បីស្គាល់ ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ យើងត្រូវការអង្គុយរិះគិត **តើនៅក្នុងភូមិភាគភ្នំពេញតាមកន្លែងដែលខ្ញុំនៅ ខ្ញុំសាបព្រោះ**

**ដូចម្ដេច?** មើលរបៀបព្រះយេស៊ូ ព្រះអង្គបានទៅតាមកន្លែងរបស់គេដើម្បីជួបគេ ដោយមិនរើសមនុស្ស ព្រះអង្គធ្វើដំណើរទៅគ្រប់ទីកន្លែងដោយឆ្លៀតឱកាសដើម្បីអប់រំ។ នៅថ្ងៃនេះ ដើម្បីបង្ហាញអំពីអំណរសប្បាយដែលព្រះជាម្ចាស់មាន នៅពេលមានមនុស្សតែម្នាក់ដែលបានកែប្រែចិត្តគំនិត។ ព្រះយេស៊ូ ឆ្លៀតឱកាសដើម្បីទៅគ្រប់ទីកន្លែងនៅក្នុងសង្គម និងដើម្បីប្រកាសដំណឹងល្អ ដោយលើកពាក្យប្រស្នាមួយដើម្បីអប់រំ ដើម្បីបំភ្លឺ ដើម្បីឲ្យគេភ្ញាក់ស្មារតី។ គេរិះគន់ព្រះយេស៊ូ គេរកមធ្យោបាយដើម្បីចាប់និងសម្លាប់ព្រះអង្គ ដោយសារគេមិនសប្បាយចិត្តព្រោះព្រះយេស៊ូបានរំខានរបៀបគេ។

ពេលខ្ញុំនៅកំពតដើម្បីបើកឆ្នាំសិក្សាថ្មី ខ្ញុំបាននៅជាមួយឪពុកម្ដាយសិស្សដែលមិនស្គាល់ព្រះសហគមន៍យើងសោះ នេះជាឱកាសមួយដើម្បីបង្កើតទំនាក់ទំនងនៅក្នុងរបៀបមួយ ដែលណែនាំឲ្យគេយល់ថាសាលារបស់យើងមិនមែនជាសាលាធម្មតាទេ ជាសាលាមួយដែលភ្ជាប់នឹងព្រះសហគមន៍កាតូលិកនៅក្នុងរបៀបណា ប្រព័ន្ធអប់រំនៅក្នុងព្រះសហគមន៍កាតូលិកគឺជាអ្វី។ ពេលខ្ញុំទៅសាលារដ្ឋ ដែលមានសិស្សជាង១៥០០នាក់ និងបុគ្គលិកសិក្សាជាង១០០នាក់ ខ្ញុំមានឱកាសដើម្បីនិយាយ យើងធ្វើដូចម្ដេចដើម្បីកសាងសិស្សានុសិស្សយ៉ាងពេញលក្ខណៈ។ ពេលខ្ញុំនិយាយអំពីប្រព័ន្ធអប់រំទាំងមូលរបស់ព្រះសហគមន៍កាតូលិក ដែលចូលគ្រប់វិស័យនៃជីវិត យើងជាមនុស្សម្នាក់ដែលចូលនៅក្នុងសង្គម នៅក្នុងវប្បធម៌ នៅក្នុងជីវិតប្រចាំ... មានទាំងរូបកាយ មានទាំងចំណេះដឹង និងមានទាំងផ្លូវវិញ្ញាណ។ ធ្វើដូចម្ដេច ដើម្បីឲ្យព្រះសហគមន៍របស់យើងមានសម្លេងខ្លះជាមួយរដ្ឋអំណាច ជាមួយរដ្ឋាភិបាល ជាមួយសង្គម ជាមួយប្រជាជន ដែលជាឱកាសដើម្បីណែនាំឲ្យបងប្អូនទាំងអស់បានស្ដាប់អំពីព្រះសហគមន៍។ សំខាន់ដើម្បីប្រកាសដំណឹងល្អដូចព្រះយេស៊ូបានសាបព្រោះនៅគ្រប់វិស័យនៃសង្គម ដើម្បីប្រកាសដំណឹងល្អនៅក្នុងរបៀបមួយ។ នៅតាមសាលាកាតូលិកដែលយើងមាន ជាឱកាសមួយដើម្បីរិះគិតពីមួយថ្ងៃទៅមួយថ្ងៃ **តើយើងប្រកាសដំណឹងល្អដូចម្ដេចដល់សិស្សដែលយើងបានទទួលនៅតាមសាលាយើង? តើយើងប្រកាសដំណឹងល្អដូចម្ដេចនៅតាមកន្លែងដែលយើងធ្វើការ?**

យើងមើលរបៀបព្រះយេស៊ូ **តើខ្ញុំធ្វើដូចម្ដេចដើម្បីណែនាំអំណរសប្បាយនៃដំណឹងល្អទៅដល់គ្រប់ទីកន្លែង?** ដូចយើងបានស្ដាប់ "**ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់ដែលនៅស្ថានបរមសុខមានអំណរសប្បាយ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ទេវទូតរបស់ព្រះជាម្ចាស់នឹងមានអំណរសប្បាយជាខ្លាំងដោយមានមនុស្សបាបតែម្នាក់កែប្រែចិត្តគំនិត**"។ គោលដៅនៃជីវិតរបស់យើង គឺទទួលសេចក្ដីសុខសាន្ត ដែលមានមូលដ្ឋានគ្រឹះនៅក្នុងអំណរសប្បាយរបស់ព្រះជាម្ចាស់ នៅក្នុងអំណរសប្បាយនៃដំណឹងល្អដែលយើងចង់ចែករំលែក។ ក្នុងរដូវបុណ្យព្រះយេស៊ូប្រសូត យើងធ្វើដូច

ម្ដេចដើម្បីឲ្យបុណ្យព្រះយេស៊ូប្រសូត ជាឱកាសមួយដើម្បីប្រកាសដំណឹងល្អថែមទៀត ដើម្បីសាបព្រោះថែមទៀត ដើម្បីឲ្យមនុស្សមួយចំនួនអាចរកឃើញជីវិតដ៏អស្ចារ្យរបស់ព្រះជាម្ចាស់នៅក្នុងមហាគ្រួសារថ្មីគឺព្រះសហគមន៍។

ថ្ងៃនេះ ដែលយើងអធិដ្ឋានសម្រាប់ការត្រាស់ហៅជាឱកាសមួយ ដើម្បីអធិដ្ឋានសម្រាប់ព្រះសហគន៍របស់យើង ឲ្យយើងមានអ្នកសាបព្រោះច្រើនថែមទៀត។ ព្រះសហគមន៍ត្រូវការបូជាចារ្យដើម្បីទៅមុខ ឲ្យយើងគិតអំពីតួនាទីរបស់យើងជាព្រះសហគមន៍ដើម្បីបង្កើតបូជាចារ្យយ៉ាងច្រើន។ ព្រះសហគមន៍ជាឪពុកម្ដាយរបស់បូជាចារ្យ ព្រះសហគមន៍នីមួយៗជាឪពុកម្ដាយនៃកូនបូជាចារ្យថ្មីៗដើម្បីបន្តប្រកាសដំណឹងល្អ។ បើព្រះសហគមន៍របស់យើងឥតមានបូជាចារ្យដើម្បីសាបព្រោះ ដើម្បីដឹកនាំ ដើម្បីអប់រំ ដើម្បីថ្វាយសក្ការៈបូជាឲ្យវត្តមានរបស់ព្រះគ្រីស្ដចូលនៅក្នុងដួងចិត្តរបស់យើង នោះព្រះសហគមន៍របស់យើងមិនអាចទៅមុខបានទេ។ កុំប្រើបូជាចារ្យយើងធ្វើដូចម្ដេចដើម្បីឲ្យបូជាចារ្យយើងមានកម្លាំងដើម្បីអធិដ្ឋាន ដើម្បីណែនាំអប់រំយើងឲ្យយើងមានជីវិតមកពីព្រះជាម្ចាស់ផ្ទាល់។ ឪពុកម្ដាយសូមគិត កុំឲ្យមានកូនបម្រើតែសង្គមនៅថ្ងៃអនាគត ឲ្យមានកូនដើម្បីបម្រើព្រះសហគមន៍ដោយធ្វើជាបូជាចារ្យផង។

យើងអធិដ្ឋាន ឲ្យមានសុខសន្តិភាពនៅក្នុងសង្គមរបស់យើង ឲ្យយើងរស់នៅក្នុងគ្រួសារតែមួយជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ អាម៉ែន៕